# ព្រះរាជក្រម

នស/រកម/០២៩៧/០២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស_៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស_រកម_០១៩៦_១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីតំបន់អាស៊ី_អាគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ មករាឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីតំបន់អាស៊ី-អាគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែរ

**មាត្រា ១.-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីតំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ ដែលចុះហត្ថលេខានៅបាងកក នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តសន្ធិសញ្ញានេះ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំរដ្ឋសភាលើកទី [illegible] នីតិកាលទី ១ ។

ភ្នំពេញ,ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ១៩៩៧

ប្រធានរដ្ឋសភា

ជា ស៊ីម

# សន្ធិសញ្ញា

## ស្តីពីតំបន់អាស៊ី - អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ

## TREATY ON THE SOUTHEAST ASIA NUCLEAR WEAPON -FREE ZONE

---

<u>បណ្តារដ្ឋភាគីនៃសន្ធិសញ្ញា</u> :

**ដោយមានបំណង** ចូលរួមធ្វើអោយបានសំរេចនូវវត្ថុបំណង និងគោលការណ៍ទាំងឡាយនៃធម្មនុញ្ញអង្គការសហប្រជាជាតិ

**ដោយប្តេជ្ញាថា** នឹងចាត់វិធានការជាក់ស្តែងដែលនឹងរួមវិភាគទានដល់ការជំរុញអោយមានការរំសាយសព្វាវុធជាទូទៅនិងទាំងស្រុង និងការជំរុញអោយមានសន្តិភាពនិងសន្តិសុខអន្តរជាតិ

**ដោយបានអះអាងជាថ្មី** ពីបំណងប្រាថ្នារបស់រដ្ឋទាំងឡាយនៅអាស៊ី-អាគ្នេយ៍ ក្នុងការរក្សាសន្តិភាព ស្ថេរភាពនៅក្នុងតំបន់ក្នុងស្មារតីសន្តិសហវិជ្ជមាន ការយោគយល់គ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការដូចដែលមានចែងនៅក្នុងសេចក្តីប្រកាស សេចក្តីថ្លែងការណ៍នានា និងលិខិតុបករណ៍ ច្បាប់ផ្សេងៗទៀត

**ដោយបានរំលឹកឡើងវិញ** នូវសេចក្តីថ្លែងការណ៍ស្តីពីតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត្យ (ZOPFAN) ដែលត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី ២៧ វិច្ឆិកា ១៩៧១ នៅទីក្រុងគូឡាលំពួរ និងគំរោងប្រតិបត្តិការជាក់ស្តែងស្តីពី ZOPFAN ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី ២៦ កាល ពីខែកក្កដា ឆ្នាំ ១៩៩៣ នៅសិង្ហបុរី

**ដោយជឿជាក់ថា** ការបង្កើត " តំបន់អាស៊ី-អាគ្នេយ៍មួយគ្មានអាវុធបរមាណូ " ជាសមាសធាតុមួយយ៉ាងសំខាន់នៃ ZOPFAN ហើយពិតជានឹងរួមចំណែកដល់ការពង្រឹងសន្តិសុខបណ្តារដ្ឋនៅក្នុងតំបន់ និងដល់ការបង្កើនសន្តិភាព និងសន្តិសុខអន្តរជាតិ

**ដោយអះអាងជាថ្មី** ពីសារៈសំខាន់នៃ សន្ធិសញ្ញាស្តីពីការមិនរីកសាយនៃអាវុធបរមាណូ (NPT) ដើម្បីទប់ស្កាត់ការរីកសាយនៃអាវុធបរមាណូ និងរួមវិភាគទានដល់សន្តិភាព និងសន្តិសុខអន្តរជាតិ

**ដោយរំលឹកឡើងវិញ** នូវមាត្រាទី៧នៃ NPT ដែលទទួលស្គាល់សិទ្ធិនៃក្រុមប្រទេសណាមួយក្នុងការចូលសន្ធិសញ្ញាតំបន់ ដើម្បីកំចាត់អាវុធនុយក្លេអ៊ែរ ពីទឹកដីរបស់ខ្លួន

**ដោយរំលឹកឡើងវិញ** ពីឯកសារចុងក្រោយនៃសម័យប្រជុំពិសេសលើកទី១០របស់មហាសន្និបាតអង្គការសហប្រជាជាតិដែលជំរុញអោយបង្កើតតំបន់គ្មានអាវុធបរមាណូ

**ដោយរំលឹកឡើងវិញនូវ** បណ្តាគោលការណ៍និងវត្ថុបំណងនៃការមិនរីកសាយអាវុធបរមាណូ និងការរំសាយសព្វាវុធ ដែលត្រូវបានអនុម័តក្នុងសន្និសីទស្តីពីការពិនិត្យមើលឡើងវិញនិងការបន្តរបស់ភាគីនៃសន្ធិសញ្ញានេះនាឆ្នាំ១៩៩៥ ដែលបានបញ្ជាក់ថា កិច្ចសហប្រត្តិបត្តិការ ការគោរពនិងការគាំទ្រពីសំណាក់ប្រទេសទាំងអស់ដែលមានអាវុធបរមាណូ ចំពោះពិធីសារពាក់ព័ន្ធមានសារៈសំខាន់ដើម្បីធ្វើអោយសន្ធិសញ្ញាស្តីពីតំបន់គ្មានអាវុធបរមាណូ និងពិធីសារពាក់ព័ន្ធទាំងឡាយនោះមានប្រសិទ្ធភាពជាអតិបរមា

**ដោយម្តេញ្ជា** ការពារតំបន់តទល់នឹងភាពពុលបរិដ្ឋាន និងគ្រោះថ្នាក់ទាំងឡាយបណ្តាលមកពីកាកសំណល់វិទ្យុសកម្ម និងវត្ថុធាតុវិទ្យុសកម្មផ្សេងទៀត

**<u>បានព្រមព្រៀងដូចតទៅ</u>** :

## <u>មាត្រាទី ១</u>

## ការប្រើប្រាស់ពាក្យពេចន៍

<u>សំរាប់វត្ថុបំណងនៃសន្ធិសញ្ញា និងពិធីសារពាក់ព័ន្ធនេះ :</u>

ក- " តំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធបរមាណូ " បន្ទាប់ទៅនេះហៅថា " តំបន់ " គឺជាភូមិភាគមួយដែលមានទឹកដីនៃបណ្តាប្រទេសអាស៊ី-អាគ្នេយ៍ទាំងអស់គឺ ប្រ៊ុយណៃដារូស្សាឡាម កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ារ ហ្វីលីពីន សឹង្ហបូរី ថៃឡង់ដ៍ និង វៀតណាម ព្រមទាំងតំបន់ខ្ពង់រាបបាតសមុទ្រ និងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) នៃប្រទេសទាំងនេះផង ។

ខ- " ទឹកដី " មានន័យថា : ដែនដីគោក ដែនទឹកនៅក្នុងប្រទេស ដែនសមុទ្រ ដែនទឹកជុំវិញប្រជុំកោះ ផ្ទៃដីបាតសមុទ្រ ដីក្រោមបាតសមុទ្រ និងដែនអាកាសពីលើទឹកដី ។

គ- " អាវុធបរមាណូ " មានន័យថា គ្រឿងនិងជាតិផ្ទុះទាំងឡាយដែលអាចបញ្ចេញថាមពលបរមាណូពុំអាចគ្រប់គ្រងបាន ប៉ុន្តែមិនរាប់បញ្ចូលមធ្យោបាយដឹកជញ្ជូន ឬ ការផ្តល់គ្រឿងនិងជាតិផ្ទុះទាំងនោះប្រសិនបើវាស្ថិតនៅដាច់ពីគ្នា ហើយមិនមែនជាផ្នែក១មួយបំបែកមិនបាននោះទេ ។

ឃ- " ការតាំង " មានន័យថា ការបញ្ចេញ (Deploy) ការតាំង (Emplace) ការបញ្ចុះ (Implant) ការតម្លើង (Install) ការស្តុក (Stockpile) ឬការដាក់ក្នុងឃ្លាំង (Store)

ង- " ធាតុវិទ្យុសកម្ម " មានន័យថា ជាធាតុទាំងឡាយណាដែលមានជាតិវិទ្យុសកម្ម Radionuclide ដែលលើសពីកំរិតអនុញ្ញាត ឬ លើសពីកំរិតលើកលែងពីសំណាក់ភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA)

ច- " កាកសំណល់វិទ្យុសកម្ម " មានន័យថា ជាធាតុមានសារជាតិ ឬ ឆ្លងដោយជាតិវិទ្យុសកម្ម Radionuclide ខាប់ ឬមានសកម្មភាពលើសពីការកំរិតអនុញ្ញាតដោយ IAEA ហើយដែលគ្មានគំរោងយកមកប្រើទៅថ្ងៃក្រោយឡើយ និង

ឆ- " ការចាក់កាកសំណល់ " (Dumping) មានន័យថា

១- ការចាក់ចោលដោយចេតនាទៅក្នុងសមុទ្រដែលមានរួមទាំងបាតសមុទ្រនិងដីកកប់ក្នុងដីក្រោមបាតសមុទ្រនូវកាកសំណល់វិទ្យុសកម្ម ឬវត្ថុធាតុផ្សេងទៀតពីនាវាឬយន្តហោះ ស្ថានីយឬសំណង់ ផ្សេងទៀតនៅផ្ទៃសមុទ្រ និង

២- រាល់ការចាក់ចោលដោយចេតនាទៅក្នុងសមុទ្រ ដោយរាប់បញ្ចូលទាំងបាតសមុទ្រ និងកប់ក្រោមបាតសមុទ្រនូវនាវា យន្តហោះ ស្ថានីយរុករកប្រេង ឬ សំណង់ផ្សេងទៀតនៅផ្ទៃសមុទ្រដែលមានសារជាតិវិទ្យុសកម្ម ប៉ុន្តែមិនរាប់បញ្ចូលការចាក់កាកសំណល់ ឬ សំរាមបន្ទាប់បន្សំទៅនឹង ឬ ផ្ទេរចេញពីនាវា យន្តហោះ ស្ថានីយរុករកប្រេង ឬ សំណង់ និងគ្រឿងឧបករណ៍ផ្សេងទៀត ក្នុងកិច្ចប្រតិបត្តិធម្មតារបស់គេ ផ្សេងពីកាកសំណល់និងវត្ថុផ្សេងទៀត ដឹកដោយ ឬដឹកទៅដាក់ផ្ទុកទៅនឹងនាវា យន្តហោះ ស្ថានីយរុករកប្រេង ឬ សំណង់ផ្សេងទៀតនៅផ្ទៃសមុទ្រ ដែលមានមុខប្រតិបត្តិការចាក់ចោលវត្ថុនោះ ឬ វត្ថុដែលចំរាញ់ចេញពីកាកសំណល់នោះ ឬវត្ថុផ្សេងទៀតនៅលើនាវា យន្តហោះ ស្ថានីយរុករកប្រេង ឬសំណង់ទាំងនោះ ។

## មាត្រាទី ២

## ការអនុវត្តនៃសន្ធិសញ្ញា

១-សន្ធិសញ្ញា និងពិធីសារនេះ ត្រូវយកទៅអនុវត្តនៅលើទឹកដីខ្ពង់រាបបាតសមុទ្រនិងតំបន់សេដ្ឋកិច្ចផ្តាច់មុខនៃបណ្តារដ្ឋជាភាគីនៅក្នុងរង្វង់តំបន់ដែលសន្ធិសញ្ញានេះមានជាធរបញ្ញត្តិ ។

២-គ្មានចំណុចណាមួយនៃសន្ធិសញ្ញានេះធ្វើអោយប៉ះពាល់ដល់សិទ្ធិ ឬការប្រើសិទ្ធិរបស់រដ្ឋណាមួយដែលមានចែងក្នុង ខ ទាំងឡាយនៃកតិកាសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២នោះទេ ជាពិសេសចំពោះសេរីភាពនៅសមុទ្រខាងក្រៅ សិទ្ធឆ្លងកាត់ដោយគ្មានបំណងអាក្រក់ ឬ ដំណើរឆ្លងកាត់តាមប្រជុំកោះ ឬការឆ្លងកាត់នៃនាវា ឬយន្តហោះដែលស្របទៅនឹង ធម្មនុញ្ញអង្គការសហប្រជាជាតិ ។

## មាត្រាទី ៣

## ការសន្យាជាមូលដ្ឋាន

១- ទោះនៅកន្លែងណាក៏ដោយ មិនថាឡើយនៅក្នុង ឬក្រៅតំបន់ រដ្ឋជាភាគីនិមួយៗសន្យាមិន :

ក- កសាង ផលិត ឬ ទទួលយក ធ្វើជាម្ចាស់កម្មសិទ្ធិ ឬត្រួតត្រាលើអាវុធនុយក្លេអ៊ែរតាមវិធីណាមួយ

ខ- ដាក់តាំង ឬ ដឹកជញ្ជូនអាវុធនុយក្លេអ៊ែរតាមមធ្យោបាយណាក៏ដោយ ឬ

គ- ធ្វើការសាកល្បង ឬ ប្រើប្រាស់អាវុធនុយក្លេអ៊ែរ

២- រដ្ឋជាភាគីនិមួយៗ ត្រូវសន្យាផងដែរថា មិនអនុញ្ញាតអោយរដ្ឋដទៃទៀតប្រើទឹកដីខ្លួនសំរាប់ :

ក- កសាង ផលិត ឬ ទទួលយក ធ្វើជាម្ចាស់កម្មសិទ្ធិ ឬត្រួតត្រាលើអាវុធនុយក្លេអ៊ែរតាមវិធីណាមួយ

ខ- ដាក់តាំងអាវុធនុយក្លេអ៊ែរ

គ- សាកល្បង ឬ ប្រើប្រាស់អាវុធនុយក្លេអ៊ែរ

៣- រដ្ឋជាភាគីនិមួយៗត្រូវប្រកាន់ខ្ជាប់ផងដែរថាមិនត្រូវ :

ក. ចាក់ចូលទៅក្នុងសមុទ្រ ឬ បញ្ចេញទៅក្នុងលំហអាកាសក្នុងរង្វង់តំបន់នូវវត្ថុធាតុ និងកាកសំណល់ដែលមានសារជាតិវិទ្យុ សកម្ម

ខ. ចាក់វត្ថុធាតុ ឬកាកសំណល់ដែលមានសារជាតិវិទ្យុសកម្មលើដី ដែលស្ថិតនៅលើទឹកដី (នៃរដ្ឋផ្សេង) ឬដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃរដ្ឋផ្សេង លើកលែងតែក្នុងករណីដូចមានចែងក្នុងកថាខ័ណ្ឌទី២ (ង) នៃមាត្រា៤ ឬ

គ. អនុញ្ញាតអោយប្រទេសផ្សេងចាក់វត្ថុធាតុ ឬកាកសំណល់ដែលមានសារជាតិវិទ្យុសកម្មចូលទៅក្នុង សមុទ្រ ឬបញ្ចេញទៅក្នុងលំហអាកាសដែលស្ថិតនៅលើទឹកដីខ្លួន

៤- រដ្ឋជាភាគីនិមួយៗត្រូវប្រកាន់ខ្ជាប់ថាមិន :

ក- ស្វែងរក ឬ ទទួលជំនួយដើម្បីធ្វើសកម្មភាពបំពានទៅលើ ខ ទាំងឡាយនៃកថាខ័ណ្ឌទី១ ទី២ និងទី៣ នៃមាត្រានេះ ឬ

ខ- ចាត់វិធានការណាមួយសំរាប់ជួយឧបត្ថម្ភ ឬលើកទឹកចិត្តក្នុងការធ្វើសកម្មភាពណាមួយដែលបំពានទៅលើ ខ ទាំងឡាយនៃកថាខ័ណ្ឌទី១ ទី២ ទី៣ នៃមាត្រានេះ ។

## មាត្រាទី ៤

## ការប្រើប្រាស់ថាមពលនុយក្លេអ៊ែរក្នុងគោលបំណងសន្តិភាព

១- ក្នុងសន្ធិសញ្ញានេះ គ្មានចំណុចណាមួយដែលប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋទាំងឡាយដែលជាភាគីក្នុងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ជាពិសេសក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវឌ្ឍនសង្គមរបស់គេទេ

២- ដូច្នេះរដ្ឋជាភាគីត្រូវប្រកាន់ខ្ជាប់ :

ក-ប្រើប្រាស់វត្ថុធាតុ និងរោងចក្រនុយក្លេអ៊ែរ ដែលមាននៅក្នុងទឹកដី ឬតំបន់នៅក្រោមការគ្រប់គ្រងនិងការត្រួតត្រារបស់ខ្លួនដើម្បីក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ

ខ- មុននឹងចាប់ផ្ដើមកសាងគំរោងថាមពលនុយក្លេអ៊ែរក្នុងគោលបំណងសន្តិភាព ត្រូវដាក់គំរោងនោះអោយមានការវាយតម្លៃអំពីសុវត្ថិភាពយ៉ាងហ្មត់ចត់បំផុតស្របតាមការណែនាំ និងខ្នាតដែលលើកឡើងដោយ IAEA ភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ក្នុងការការពារសុខភាព និងបន្ថយជាអប្បបរមានូវគ្រោះថ្នាក់ដល់ជីវិត និង ដល់ទ្រព្យសម្បត្តិស្របតាម កថាខ័ណ្ឌទី៦ មាត្រាទី៣ នៃលក្ខន្តិកៈរបស់ភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA)

គ- ដាក់អោយមានការវាយតំលៃពីសំណាក់រដ្ឋជាភាគីមួយទៀតប្រសិនមានសំណូមពរ លើកលែងតែពត៌មានដែលទាក់ទងដល់ឯកសារផ្ទាល់ខ្លួន ពត៌មានដែលទទួលការការពារដោយច្បាប់កម្មសិទ្ធិបញ្ញា ឬពត៌មានដែលស្ថិតក្រោមការសំងាត់ខាងឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងពត៌មានដែលទាក់ទងដល់សន្តិសុខជាតិ

ឃ- គាំទ្រដល់ប្រសិទ្ធភាពជាប្រចាំរបស់ប្រព័ន្ធអន្តរជាតិនៃការមិនរីកសាយអាវុធ ដែលឈរលើសន្ធិសញ្ញា NPT និង IAEA និង

ង-ចាក់ចោលកាកសំណល់ ឬវត្ថុធាតុផ្សេងទៀតដែលមានសារជាតិវិទ្យុសកម្មស្របតាមខ្នាត និងនីតិវិធីរបស់ភ្នាក់ងារថាមពលបរមាណូអន្តរជាតិ លើដី ក្នុងទឹកដីរបស់ខ្លួន ឬលើដី ក្នុងទឹកដីរបស់ប្រទេសមួយទៀតដោយមានការអនុញ្ញាតយល់ព្រមពីសាមីប្រទេស

៣- រដ្ឋជាភាគីនិមួយៗ ត្រូវប្រកាន់ខ្ជាប់ផងដែរថា មិនផ្ដល់ប្រភព ឬគ្រឿងងាយផ្ទុះពិសេស ឬ បរិក្ខា ឬក៏វត្ថុដែលបានគ្រោង ឬរៀបចំឡើងក្នុងគោលបំណង ពិសេសសំរាប់ការកែច្នៃ ការប្រើប្រាស់ ឬក៏ការផលិតវត្ថុងាយផ្ទុះ ពិសេសដល់ :

ក. ប្រទេសណាដែលគ្មានអាវុធនុយក្លេអ៊ែរ លើកលែងតែនៅក្នុងលក្ខខ័ណ្ឌទាំងឡាយតម្រូវអោយមានការការពារដែលមានចែងនៅក្នុងកថាខ័ណ្ឌទី១ មាត្រាទី៣ នៃ " សន្ធិសញ្ញាមិនរីកសាយអាវុធនុយក្លេអ៊ែរ " (NPT) ឬក៏

ខ. ប្រទេសណាដែលមានអាវុធនុយក្លេអ៊ែរលើកលែងតែអនុលោមទៅតាមកិច្ចព្រមព្រៀងនានាជាមួយភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ស្តីពីការការពារដែលអាចអនុវត្តបាន

## មាត្រាទី ៥

## ច្បាប់ការពារនៃភ្នាក់ងារថាមពលបរមាណូអន្តរជាតិ

រដ្ឋជាភាគីនីមួយៗដែលមិនទាន់បានធ្វើដូច្នេះនៅឡើយ ត្រូវចុះកិច្ចព្រមព្រៀងជាមួយភ្នាក់ងារថាមពលបរមាណូអន្តរជាតិដើម្បីអនុវត្តការពារសុវត្ថិភាពបានពេញលេញក្នុងសកម្មភាពនុយក្លេអ៊ែរក្នុងគោលដៅសន្តិភាពរបស់ខ្លួនមិនអោយយឺតជាងពី១៨ខែ បន្ទាប់ពីការចូលជាធរមាននៃសន្ធិសញ្ញាសំរាប់រដ្ឋជាភាគី ។

## មាត្រាទី ៦

## ការជូនដំណឹងជាបន្ទាន់ពីគ្រោះថ្នាក់នុយក្លេអ៊ែរ

រដ្ឋជាភាគីនីមួយៗដែលមិនទាន់បានចូលកតិកាសញ្ញានៃការជូនដំណឹងជាបន្ទាន់ពីគ្រោះថ្នាក់នុយក្លេអ៊ែរ ត្រូវខិតខំចូលកតិការនោះ ។

## មាត្រាទី ៧

## នាវា និងយន្តហោះបរទេស

រដ្ឋជាភាគីនីមួយៗ នៅពេលបានទទួលការជូនដំណឹងហើយ អាចសំរេចដោយខ្លួនឯងក្នុងការអនុញ្ញាតអោយនាវា និងយន្តហោះបរទេសចូលចតនៅកំពង់ផែ ឬចុះចតនៅចំណតយន្តហោះរបស់ខ្លួនអោយនាវា ឬយន្តហោះបរទេសបើកបរឆ្លងដែនអាកាស ដែនសមុទ្ររបស់ខ្លួន ឬតាមដែនទឹកជុំវិញប្រជុំកោះ និងអោយហោះហើរឆ្លងកាត់ដែនអាកាសពីលើដែនទឹកទាំងអស់នោះ ក្នុងបែបបទដែលមិនចំណុះក្នុងសិទ្ធិនៃការឆ្លងកាត់ដោយសុធន្ទះ ដំណើរឆ្លងកាត់តាមចន្លោះប្រជុំកោះ ឬផ្លូវឆ្លងកាត់ ។

## មាត្រាទី ៨

## ការបង្កើតគណៈកម្មការសំរាប់តំបន់អាស៊ី-អាគ្នេយ៍ គ្មានអាវុធនុយក្លេអ៊ែរ

១- គណៈកម្មការមួយបានត្រូវបង្កើតឡើងសំរាប់តំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ ដែលហៅថា " គណៈកម្មការ "

២- រដ្ឋភាគីទាំងអស់ គឺជាសមាជិកតាមការជាក់ស្តែង (ipso facto) នៃគណៈកម្មការនេះ ។ រដ្ឋភាគីនិមួយៗត្រូវតំណាងឡើងដោយរដ្ឋមន្ត្រីការបរទេស ឬតំណាងរបស់រដ្ឋមន្ត្រីនេះ អមដោយមន្ត្រីបំរុង និងទីប្រឹក្សា ។

៣- ភារកិច្ចនៃ " គណៈកម្មការ " គឺត្រួតពិនិត្យមើលការអនុវត្តសន្ធិសញ្ញានេះ និងធានាការគោរពនូវខ ទាំងឡាយនៃសន្ធិសញ្ញានេះ ។

៤- គណៈកម្មការនេះត្រូវធ្វើការប្រជុំតាមពេលវេលាសមស្រប និងចាំបាច់ដោយអនុលោមទៅតាមខទាំងឡាយនៃសន្ធិសញ្ញានេះ តាមសំណើរបស់រដ្ឋភាគីណាមួយ។ គណៈកម្មការនឹងត្រូវបើកកិច្ចប្រជុំទៅតាមលទ្ធភាពអោយស្របពេលនឹងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន ។

៥- នៅមុនពេលកិច្ចប្រជុំនិមួយៗ គណៈកម្មការត្រូវបោះឆ្នោតរើសប្រធានអង្គប្រជុំ និងមន្ត្រីឯទៀតទៅតាមតំរូវការ ។ ប្រធាននិងមន្ត្រីទាំងនោះត្រូវបំពេញតួនាទីរបស់ខ្លួនរហូតដល់មានការបោះឆ្នោតជ្រើសរើសប្រធាន និងមន្ត្រីជាថ្មី នាពេលប្រជុំលើកក្រោយ ។

៦-លើកលែងតែមានចែងផ្សេងទៀតក្នុងសន្ធិសញ្ញានេះ វត្តមានចំនួនពីរភាគបីនៃសមាជិកគណៈកម្មការនឹងចាត់ទុកជាចំនួនគ្រប់គ្រាន់សំរាប់បើកអង្គប្រជុំបាន (Quorum) ។

៧- សមាជិកនិមួយៗនៃគណៈកម្មការមានសម្លេងមួយ ។

៨- លើកលែងតែមានចែងក្នុងសន្ធិសញ្ញានេះ សេចក្តីសំរេចរបស់គណៈកម្មការត្រូវអនុម័តដោយកុងសង់ស៊ុស ឬ បើពុំមានកុងសង់ស៊ុសនោះទេ ត្រូវអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃសមាជិកដែលមានវត្តមានពេលបោះឆ្នោត ។

៩-តាមរបៀបកុងសង់ស៊ុស គណៈកម្មការត្រូវព្រមព្រៀងនិងអនុម័តលើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មការផ្ទាល់ ក៏ដូចជាលើបែបបទហិរញ្ញវត្ថុ ដែលគ្រប់គ្រងចំណូលហិរញ្ញវត្ថុរបស់គណៈកម្មការ និងសាខារបស់ខ្លួន ។

## <u>មាត្រាទី ៩</u>

## គណៈកម្មាធិការប្រតិបត្តិ

១- សាខាមួយនៃគណៈកម្មការបានត្រូវបង្កើតឡើងដែលហៅថា " គណៈកម្មាធិការប្រតិបត្តិ " ។

២- គណៈកម្មាធិការប្រតិបត្តិត្រូវមានសមាសភាពពីរដ្ឋភាគីទាំងអស់នៃសន្ធិសញ្ញានេះ ។ រដ្ឋភាគីនិមួយៗ ត្រូវតំណាងដោយមន្ត្រីជាន់ខ្ពស់ម្នាក់ ដែលអាចអមដោយបណ្តាមន្ត្រីបំរុង និងទីប្រឹក្សា ។

៣- ភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិគឺ :

ក. ធានានូវកិច្ចប្រតិបត្តិការសមស្របក្នុងវិធានការត្រួតពិនិត្យដោយអនុលោមទៅតាមខ ទាំងឡាយនៃប្រព័ន្ធត្រួតពិនិត្យ ដូចដែលមានចែងក្នុងមាត្រាទី ១០ ។

ខ. ធ្វើការពិចារណានិងសំរេចលើបណ្តឹងសំណើសុំបំភ្លឺនិងបណ្តឹងសំណើសុំបេសកកម្មស្វែងរកការពិត ។

គ. បង្កើតបេសកកម្មស្វែងរកការពិត ដោយអនុលោមទៅតាមឧបសម្ព័ន្ធនៃសន្ធិសញ្ញានេះ ។

ឃ. ពិចារណា និងសំរេចលើលទ្ធផលស្រាវជ្រាវរបស់បេសកកម្មស្វែងរកការពិត ហើយរាយការណ៍ជូនគណៈកម្មការ ។

ង. ស្នើគណៈកម្មការអោយកោះប្រជុំការងារ តាមពេលវេលាសមស្រប និងចាំបាច់

ច. ចុះកិច្ចព្រមព្រៀងជាមួយភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ឬ ជាមួយអង្គការអន្តរជាតិផ្សេងទៀត យោងទៅតាមមាត្រាទី១៨ក្នុងនាមគណៈកម្មការបន្ទាប់ពីបានទទួលការអនុញ្ញាតត្រឹមត្រូវពីគណៈ-កម្មការអោយធ្វើដូច្នេះ ហើយ

ឆ. បំពេញភារកិច្ចផ្សេងទៀត ដែលគណៈកម្មការបានប្រគល់ជូនក្នុងពេលម្តងម្កាល ។

៤- គណៈកម្មាធិការប្រតិបត្តិត្រូវធ្វើការប្រជុំនៅពេលណាចាំបាច់ ដើម្បីជំរុញអោយការអនុវត្តភារកិច្ចរបស់ខ្លួនមានប្រសិទ្ធភាព ។ គណៈកម្មាធិការប្រតិបត្តិត្រូវធ្វើការប្រជុំរបស់ខ្លួនអោយស្របទៅនឹងកិច្ចប្រជុំនៃមន្ត្រីជាន់ខ្ពស់អាស៊ានតាមលទ្ធភាពសមស្រប ។

៥- ប្រធានគណៈកម្មាធិការប្រតិបត្តិត្រូវធ្វើជាតំណាងអោយប្រធានគណៈកម្មការ ។ សំណើ ឬលិខិតស្នាមទាក់ទងជូនពត៌មានដែលរដ្ឋភាគីផ្ញើជូនទៅប្រធានគណៈកម្មាធិការប្រតិបត្តិត្រូវតែផ្សព្វផ្សាយដល់សមាជិកដទៃទៀតនៃគណៈកម្មាធិការប្រតិបត្តិ ។

៦- វត្តមានពីរភាគបី នៃសមាជិកគណៈកម្មាធិការប្រតិបត្តិជាចំនួនគ្រប់គ្រាន់សំរាប់ដំណើរការកិច្ចប្រជុំនៃគណៈកម្មាធិការនេះ (Quorum) ។

៧- សមាជិកនិមួយៗនៃគណៈកម្មាធិការប្រតិបត្តិមានសំលេងបោះឆ្នោតមួយ ។

៨- សេចក្តីសំរេចនានារបស់គណៈកម្មាធិការប្រតិបត្តិត្រូវអនុម័តដោយកុងសង់ស៊ុស ឬ បើពុំមានកុងសង់ស៊ុសទេ ត្រូវអនុម័តដោយសំលេងភាគច្រើនពីរភាគបីនៃសមាជិកដែលមានវត្តមាននាពេលបោះឆ្នោត ។

## មាត្រាទី ១០
## ប្រព័ន្ធត្រួតពិនិត្យ

១– បង្កើតប្រព័ន្ធត្រួតពិនិត្យមួយ ដើម្បីធ្វើការផ្ទៀងផ្ទាត់លើការគោរពតាមកាតព្វកិច្ចរបស់រដ្ឋភាគីនៃសន្ធិសញ្ញានេះ ។

២– ប្រព័ន្ធត្រួតពិនិត្យត្រូវមាន :

ក. ប្រព័ន្ធការពារសុវត្ថិភាពរបស់ភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ដូចមានចែងក្នុងមាត្រាទី ៥

ខ. របាយការណ៍និងផ្លាស់ប្តូរពត៌មាន ដូចមានចែងក្នុងមាត្រាទី ១១

គ. សំណើសុំការបំភ្លឺដូចមានចែងក្នុងមាត្រាទី ១២ និង

ឃ. សំណើ និងនីតិវិធីនានាសំរាប់បេសកកម្មស្វែងរកការពិត ដូចមានចែងក្នុងមាត្រាទី ១៣ ។

## មាត្រាទី ១១
## របាយការណ៍ និងការផ្លាស់ប្តូរពត៌មាន

១. រដ្ឋភាគីនិមួយៗ ត្រូវដាក់ជូនគណៈកម្មាធិការប្រតិបត្តិនូវបណ្តារបាយការណ៍ស្តីពីហេតុការណ៍ដែលគួរអោយកត់សំគាល់កើតឡើងនៅក្នុងទឹកដីខ្លួន និងតំបន់ក្រោមការគ្រប់គ្រង និងការត្រួតត្រារបស់ខ្លួនដែលប៉ះពាល់ដល់ការអនុវត្តសន្ធិសញ្ញានេះ ។

២. បណ្តារដ្ឋភាគីអាចផ្លាស់ប្តូរពត៌មានស្តីពីកិច្ចការនានាដែលលេចចេញ ឬទាក់ទងដល់សន្ធិសញ្ញានេះ ។

## មាត្រាទី ១២
## សំណើសុំការបំភ្លឺ

១– រដ្ឋភាគីនិមួយៗត្រូវមានសិទ្ធិស្នើរដ្ឋភាគីផ្សេងទៀតអោយធ្វើការបំភ្លឺពីស្ថានការណ៍ណាមួយ ដែលគេអាចចាត់ទុកថាមិនច្បាស់លាស់ ឬដែលអាចបង្កើតការមន្ទិលសង្ស័យលើរដ្ឋភាគីនោះ ក្នុងការគោរពសន្ធិសញ្ញានេះ ។ រដ្ឋភាគីនិមួយៗត្រូវជូនពត៌មានមកគណៈកម្មាធិការប្រតិបត្តិអំពីសំណើបែបនេះ ។ រដ្ឋភាគីដែលត្រូវគេស្នើនោះ ត្រូវឆ្លើយតបសមស្រប និងមិនបង្អាក់ពេលឡើយនូវពត៌មានចាំបាច់ ហើយត្រូវជំរាបជូនគណៈកម្មាធិការប្រតិបត្តិពីចម្លើយរបស់ខ្លួនចំពោះរដ្ឋភាគីជាម្ចាស់សំណើ ។

២– រដ្ឋភាគីនិមួយៗ ត្រូវមានសិទ្ធិស្នើគណៈកម្មាធិការប្រតិបត្តិអោយស្វែងរកការបំភ្លឺសំរាប់រដ្ឋភាគីផ្សេង ទៀតអំពីស្ថានការណ៍ណាមួយ ដែលអាចចាត់ទុកថាមិនច្បាស់លាស់ ឬ អាចបង្កើតការមន្ទិលសង្ស័យ

ចំពោះការគោរពសន្ធិសញ្ញានេះ ពីសំណាក់រដ្ឋភាគីនោះ ។ នៅពេលបានទទួលសំណើនោះហើយ គណៈកម្មាធិការប្រតិបត្តិត្រូវធ្វើការពិគ្រោះជាមួយរដ្ឋភាគី ដែលត្រូវផ្តល់ការស្រាយបំភ្លឺក្នុងបំណងទទួលបាននូវការបំភ្លឺតាមសំណើនោះ ។

## មាត្រាទី ១៣

## សំណើសុំបេសកកម្មស្វែងរកការពិត

រដ្ឋភាគីមួយត្រូវមានសិទ្ធិស្នើគណៈកម្មាធិការប្រតិបត្តិអោយបញ្ជូនបេសកកម្មស្វែងរកការពិតទៅរដ្ឋភាគីមួយទៀតដើម្បីបំភ្លឺ និងដោះស្រាយស្ថានភាពដែលអាចចាត់ទុកថា មិនច្បាស់លាស់ ឬអាចបង្កើតការមន្ទិលសង្ស័យលើការគោរពរបស់រដ្ឋភាគីនោះ តាម ខ ទាំងឡាយនៃសន្ធិសញ្ញាដោយអនុលោមទៅតាមនីតិវិធីដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃសន្ធិសញ្ញានេះ ។

## មាត្រាទី ១៤

## វិធានការដោះស្រាយ

១ – ក្នុងករណីដែលគណៈកម្មាធិការប្រតិបត្តិធ្វើការសំរេចដោយអនុលោមទៅតាមឧបសម្ព័ន្ធនោះ ដែលឃើញថាមានការបំពានលើសន្ធិសញ្ញាដោយរដ្ឋភាគីមួយ រដ្ឋភាគីនោះត្រូវចាត់វិធានការចាំបាច់ក្នុងពេលវេលាមួយសមស្រប ដើម្បីប្រតិបត្តិអោយបានពេញលេញតាមសន្ធិសញ្ញានោះ ហើយត្រូវជំរាបជាបន្ទាន់ដល់គណៈកម្មាធិការប្រតិបត្តិអំពីវិធានការដែលខ្លួនបានចាត់ឬ គ្រោងនឹងចាត់ ។

២ – ក្នុងករណីដែលរដ្ឋភាគីពុំបានអនុវត្ត ឬបដិសេធពុំព្រមអនុវត្តតាម ខ នៃកថាខ័ណ្ឌទី១ នៃមាត្រានេះ គណៈកម្មាធិការប្រតិបត្តិត្រូវស្នើទៅគណៈកម្មការអោយធ្វើការកោះប្រជុំមួយអនុលោមទៅតាម ខ ទាំងឡាយនៃខ័ណ្ឌទី ៣ (ង) នៃមាត្រាទី៩ ។

៣ – នៅក្នុងកិច្ចប្រជុំដោយយោលតាមកថាខ័ណ្ឌទី២នៃមាត្រានេះ គណៈកម្មការត្រូវពិចារណាលើស្ថានការណ៍ដែលកើតឡើង ហើយត្រូវសំរេចយកវិធានការណ៍ណាមួយដែលគណៈកម្មការចាត់ទុកថាសមស្របដើម្បីដោះស្រាយស្ថានភាពនោះ ដោយរាប់បញ្ចូលទាំងការដាក់បញ្ហានោះជូនភ្នាក់ងារថាមពលបរមាណូអន្តរជាតិ និងដល់ក្រុមប្រឹក្សាសន្តិសុខព្រមទាំងមហាសន្និបាតអង្គការសហប្រជាជាតិ នៅពេលដែលស្ថានភាពនោះអាចធ្វើការគម្រាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ ។

៤– ក្នុងករណីមានការបំពានលើពិធីសារភ្ជាប់នឹងសន្ធិសញ្ញានេះដោយរដ្ឋភាគីមួយនៃពិធីសារនេះ គណៈកម្មាធិការប្រតិបត្តិត្រូវកោះប្រជុំពិសេសនៃគណៈកម្មការ ដើម្បីសំរេចយកវិធានការសមស្របដែលត្រូវអនុវត្ត ។

## មាត្រាទី ១៥

## ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការចូលជាភាគី ការតំកល់ឯកសារ និងការចុះបញ្ជី

១– សន្ធិសញ្ញានេះត្រូវបើកចំហអោយរដ្ឋទាំងអស់នៅអាស៊ី-អាគ្នេយ៍ ដែលមាន ប្រ៊ុយណេដារុស្សាឡាម កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ារ ហ្វីលីពីន សិង្ហបុរី ថៃឡង់ដ៍ និងវៀតណាម ចុះហត្ថលេខា ។

២– សន្ធិសញ្ញានេះទាមទារអោយមានការផ្តល់សច្ចាប័ន ស្របតាមនីតិវិធីធម្មនុញ្ញនៃរដ្ឋហត្ថលេខី ។ លិខិតុបករណ៍ផ្តល់សច្ចាប័ននោះ ត្រូវតំកល់ទុកជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ដែលត្រូវបានចាត់តាំងជារដ្ឋតំកល់ឯកសារនេះ ។

៣– សន្ធិសញ្ញានេះនឹងបើកចំហសំរាប់ការចូលជាភាគី ។ លិខិតុបករណ៍នៃការចូលជាភាគីនឹងត្រូវតំកល់ទុកនៅរដ្ឋតំកល់ឯកសារ ។

៤– រដ្ឋតំកល់ឯកសារត្រូវជូនពតិមានដល់រដ្ឋភាគីឯទៀតនៃសន្ធិសញ្ញានេះអំពីការតំកល់ទុកនៃលិខិតុប-ករណ៍ផ្តល់សច្ចាប័ន ឬ លិខិតុបករណ៍នៃការចូលជាភាគី ។

៥– រដ្ឋតំកល់ឯកសារត្រូវចុះបញ្ជីសន្ធិសញ្ញានេះ និងពិធីសារនៃសន្ធិសញ្ញានេះយោងតាមមាត្រាទី១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

## មាត្រាទី ១៦

## ការចូលជាធរមានបញ្ញត្តិ

១. សន្ធិសញ្ញានេះត្រូវចូលជាធរមានបញ្ញត្តិ នៅថ្ងៃដែលលិខិតុបករណ៍ទី៧ នៃការផ្តល់សច្ចាប័ននិងឬការចូលជាភាគីបានត្រូវតំកល់ ។

២. ចំពោះរដ្ឋដែលផ្តល់សច្ចាប័ន ឬ ចូលជាភាគីនៃសន្ធិសញ្ញានេះក្រោយថ្ងៃតំកល់លិខិតុបករណ៍ទី៧ នៃការផ្តល់សច្ចាប័ន ឬលិខិតុបករណ៍នៃការចូលជាភាគី សន្ធិសញ្ញាត្រូវចូលជាធរមាននៅថ្ងៃដែលគេតំកល់ទុកលិខិតុបករណ៍ ឬការចូលជាភាគីនៃរដ្ឋនោះ ។

## មាត្រាទី ១៧

### ការមិនស្រប (RESERVATIONS)

សន្ធិសញ្ញានេះមិនអនុញ្ញាតអោយមានការមិនស្របទេ ។

## មាត្រាទី ១៨

### ទំនាក់ទំនងជាមួយអង្គការអន្តរជាតិផ្សេងៗ

គណៈកម្មការអាចសំរេចចុះកិច្ចព្រមព្រៀងនានាបែបនេះ ជាមួយភ្នាក់ងារថាមពលបរមាណូអន្តរជាតិ ឬជាមួយអង្គការអន្តរជាតិផ្សេងទៀត បើយល់ឃើញថាអាចសំរួលកិច្ចប្រតិបត្តិការដ៏មានប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យដែលបង្កើតឡើងដោយសន្ធិសញ្ញានេះ ។

## មាត្រាទី ១៩

### វិសោធនកម្ម

១. រដ្ឋភាគីណាមួយក៏អាចស្នើសុំធ្វើវិសោធនកម្មលើសន្ធិសញ្ញានេះ និងពិធីសារបស់វាបានដែរ ហើយត្រូវដាក់សំណើរបស់ខ្លួនជូនគណៈកម្មាធិការប្រតិបត្តិ ដែលត្រូវបញ្ជូនសំណើទាំងនោះជូនរដ្ឋភាគីដទៃទៀត ។ គណៈកម្មាធិការប្រតិបត្តិត្រូវស្នើភ្លាមដល់គណៈកម្មការអោយធ្វើការកោះប្រជុំមួយ ដើម្បីពិនិត្យសំណើធ្វើវិសោធនកម្មនោះ ។ ចំនួនវត្តមានគ្រប់គ្រាន់ទុកជាបានការដើម្បីធ្វើកិច្ចប្រជុំបែបនេះ (Quorum) ត្រូវអោយមានវត្តមានសមាជិកទាំងអស់នៃគណៈកម្មការ ។ វិសោធនកម្មណាមួយត្រូវតែអនុម័តដោយកុងសង់ស៊ុសពីគណៈកម្មការ ។

២. វិសោធនកម្មនានាដែលបានអនុម័តហើយ ត្រូវចូលជាធរមានបញ្ញត្តិ៣០ថ្ងៃក្រោយពេលដែលរដ្ឋតំកល់ឯកសារបានទទួលលិខិតុបករណ៍ទី៧ នៃការយល់ព្រមរបស់រដ្ឋបណ្តាភាគី ។

## មាត្រាទី ២០

### ការពិនិត្យឡើងវិញ

ដប់ឆ្នាំក្រោយពេលនៃការចូលជាធរមានបញ្ញត្តិនៃសន្ធិសញ្ញានេះ គណៈកម្មការត្រូវកោះកិច្ចប្រជុំដើម្បីពិនិត្យឡើងវិញនូវការប្រតិបត្តិការនៃសន្ធិសញ្ញានេះ ។ គណៈកម្មការក៏អាចកោះប្រជុំក្នុងគោលបំណងដូចគ្នានេះនៅពេលណាមួយបន្ទាប់មកទៀត ប្រសិនបើមានកុងសង់ស៊ុសក្នុងចំណោម សមាជិកទាំងអស់ ។

## មាត្រាទី ២១

### ដំណោះស្រាយជម្លោះ

ជម្លោះណាមួយដែលកើតឡើងពីការបកស្រាយ ឬ ទាំងឡាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយដោយសន្តិវិធីដូចដែលតាមការព្រមព្រៀងគ្នារវាងបណ្តារដ្ឋភាគីនៃជម្លោះនោះ ។ ប្រសិនបើក្នុងរយៈពេលមួយខែរដ្ឋភាគីនៃជម្លោះមិនអាចសំរេចបាននូវដំណោះស្រាយចំពោះជំលោះនោះដោយសន្តិវិធីតាមការចរចា ការសំរួលគ្នាតាមរយៈអាជ្ញាកណ្តាល ការធ្វើអង្កេត ឬការស្រុះស្រួលគ្នា ភាគីពាក់ព័ន្ធណាមួយត្រូវបញ្ជូនជម្លោះនេះទៅអាជ្ញាកណ្តាលអាកាត់ ឬទៅតុលាការអន្តរជាតិដោយមានការយល់ព្រមជាមុនពីភាគីម្ខាងទៀត ។

## មាត្រាទី ២២

### ថេរៈវេលា និងការសុំដកខ្លួន

១. សន្ធិសញ្ញានេះស្ថិតនៅមានតម្លៃដោយគ្មានកាលកំណត់ ។

២. ក្នុងករណីដែលរដ្ឋភាគីណាមួយនៃសន្ធិសញ្ញាល្មើសនឹងសន្ធិសញ្ញានេះ ដែលប៉ះពាល់ពិសេសដល់ការសំរេចគោលដៅទាំងឡាយនៃសន្ធិសញ្ញានេះ រដ្ឋភាគីដទៃទៀតនឹងត្រូវមានសិទ្ធិសុំដកខ្លួនចេញពីសន្ធិសញ្ញា ។

៣. ការដកខ្លួនចេញដូចមានចែងក្នុងកថាខ័ណ្ឌទី២ នៃមាត្រាទី ២២ នឹងមានប្រសិទ្ធភាពតាមការជូនដំណឹងជាមុនចំនួន ១២ ខែទៅ សមាជិកទាំងឡាយនៃគណៈកម្មការ ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខី បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើនៅបាងកក, ថ្ងៃទី ដប់ប្រាំ ខែធ្នូ ឆ្នាំមួយពាន់ប្រាំបួនរយកៅសិបប្រាំ ច្បាប់ដើមជាភាសាអង់គ្លេស ។

ហត្ថលេខា

ក្នុងនាម ប្រ៊ូណៃ ដារូស្សាឡាម

**ហាស្ស៊ី ហាស្សាណាល់ បូលគៀស់**

ស៊ុលតង់នៃប្រ៊ូណៃ ដារូស្សាឡាម

ក្នុងនាម ព្រះរាជាណាចក្រកម្ពុជា

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** — នាយករដ្ឋមន្ត្រីទីមួយ

**សម្តេច ហ៊ុន សែន** — នាយករដ្ឋមន្ត្រីទីពីរ

ក្នុងនាម សាធារណរដ្ឋ ឥណ្ឌូណេស៊ី

**ស៊ូហារតូ**

ប្រធានាធិបតី

ក្នុងនាម សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

**ខាម់តៃ ស៊ីផាន់ដន**

នាយករដ្ឋមន្ត្រី

ក្នុងនាម ម៉ាឡេស៊ី

**បណ្ឌិត មហាធៀ ប៊ីន មហាមាត់**

នាយករដ្ឋមន្ត្រី

ក្នុងនាម សហភាពមីយ៉ាន់ម៉ារ

**ឧត្តមសេនីយផុតលេខ ថាន់ ស្វេ**

ប្រធានក្រុមប្រឹក្សាស្តារច្បាប់ និងសណ្តាប់ធ្នាប់សង្គម

និងជានាយករដ្ឋមន្ត្រី

ក្នុងនាម សាធារណរដ្ឋ ហ្វីលីពីន

**ហ្វីដែល វ៉ី. រ៉ាម៉ូស**

ប្រធានាធិបតី

ក្នុងនាម សាធារណរដ្ឋ សិង្ហបុរី

**ហ្គូ ចុក តុង**

នាយករដ្ឋមន្ត្រី

ក្នុងនាម ព្រះរាជាណាចក្រថៃឡង់ដ៍

**បាន ស៊ីលប៉ា អាចា**

នាយករដ្ឋមន្ត្រី

ក្នុងនាម សាធារណរដ្ឋសង្គមនិយមវៀតណាម

**វ៉ូ វ៉ាន់ គៀត**

នាយករដ្ឋមន្ត្រី

# ឧបសម្ព័ន្ធ

## នីតិវិធីនៃបេសកកម្មស្វែងរកការពិត

១. រដ្ឋភាគីដែលស្នើសុំបេសកកម្មស្វែងរកការពិតមួយ ដូចមានចែងក្នុងមាត្រាទី១៣ ដែលក្នុងទីនេះហៅកាត់ថា " រដ្ឋស្នើសុំ " ត្រូវដាក់ពាក្យសុំទៅគណៈកម្មាធិការប្រតិបត្តិ ដោយបញ្ជាក់ដូចខាងក្រោម :

ក. ការសង្ស័យ ឬការព្រួយបារម្ភ និងមូលហេតុនៃការសង្ស័យ ឬការព្រួយបារម្ភទាំងអស់នោះ

ខ. ទីកន្លែងស្ថានការណ៍ដែលនាំអោយមានមន្ទិលសង្ស័យបានកើតឡើង

គ. បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃសន្ធិសញ្ញាដែលការមន្ទិលសង្ស័យក្នុងការអនុវត្តបានកើតឡើង និង

ឃ. ពត៌មានពាក់ព័ន្ធផ្សេងៗទៀត ។

២. នៅពេលបានទទួលសំណើសុំបេសកកម្មស្វែងរកការពិត គណៈកម្មាធិការប្រតិបត្តិត្រូវ:

ក- ជូនដំណឹងជាបន្ទាន់អំពីការទទួលសំណើទៅរដ្ឋភាគី ដែលបេសកកម្មស្វែងរកការពិតត្រូវបញ្ជូនទៅ ដែលក្នុងទីនេះហៅកាត់ថា " រដ្ឋទទួល " អំពីការទទួលសំណើ និង

ខ-មិនត្រូវអោយយឺតជាងបីសប្តាហ៍បន្ទាប់ពីបានទទួលនូវសំណើត្រូវសំរេចថា លើសំណើនោះស្របតាម ខ ក្នុងកថាខ័ណ្ឌទាំងឡាយឬទេ ហើយទោះជាសំណើនោះគ្មានសារៈសំខាន់ជាការរំលោភ ឬក៏ហួសពីក្របខ័ណ្ឌនៃសន្ធិសញ្ញាក៏ដោយ ។ ទាំងរដ្ឋស្នើសុំ ទាំងរដ្ឋទទួលមិនត្រូវចូលរួមក្នុងការសំរេចនេះទេ ។

៣. ក្នុងករណីដែលគណៈកម្មាធិការប្រតិបត្តិសំរេចថា សំណើនោះមិនសមស្របទៅតាម ខ នៃកថាខ័ណ្ឌទាំងឡាយ ឬសំរេចថាមិនសំខាន់ ជាការរំលោភ ឬហួសពីក្របខ័ណ្ឌរបស់សន្ធិសញ្ញា សំណើនេះមិនត្រូវបានយកមកដោះស្រាយទៀតទេ ហើយគណៈកម្មាធិការត្រូវជូនដំណឹងទៅរដ្ឋស្នើសុំ និងរដ្ឋទទួល តាមការគួរ ។

៤. ក្នុងករណីដែលគណៈកម្មាធិការប្រតិបត្តិសំរេចថា សំណើនោះស្របទៅតាមកថាខ័ណ្ឌទី១ និងថាសំណើនោះសំខាន់គ្មានការរំលោភ ត្រឹមត្រូវតាមក្របខ័ណ្ឌនៃសន្ធិសញ្ញា ត្រូវបញ្ជូនជាបន្ទាន់ទៅប្រទេសអ្នកទទួលនូវសំណើសុំបេសកកម្មស្វែងរកការពិត ដោយបញ្ជាក់ពីកាលបរិច្ឆេទសំរាប់បញ្ជូនក្រុមបេសកកម្ម ។ គំរោងកាលបរិច្ឆេទមិនត្រូវអោយយឺតជាងពាអាទិត្យទេ ចាប់ពីពេលដែលរដ្ឋទទួលបានទទួលសំណើសុំបេសកកម្មស្វែងរកការពិត ។ គណៈកម្មាធិការប្រតិបត្តិត្រូវបង្កើតឡើងជាបន្ទាន់នូវក្រុមបេសកកម្មស្វែងរកការពិតមួយដែលមានអធិការ ៣ រូប ពីភ្នាក់ងារបរមាណូអន្តរជាតិ ដោយអ្នកទាំងនោះមិនមានសញ្ជាតិជាប្រទេសស្នើ ឬក៏ជាប្រទេសទទួលទេ ។

៥. ប្រទេសអ្នកទទួលត្រូវអនុវត្តន៍តាមសំណើសុំក្រុមបេសកកម្មស្វែងរកការពិត យោងតាមកថាខ័ណ្ឌទី៤។ ប្រទេសអ្នកទទួលត្រូវសហការជាមួយគណៈកម្មាធិការប្រតិបត្តិដើម្បីជួយសំរួលអោយដំណើរការរបស់ក្រុមបេសកកម្មស្វែងរកការពិតមានប្រសិទ្ធភាពដូចជា សំរួលអោយក្រុមបេសកកម្មស្វែងរកការពិតចូលទៅកាន់កន្លែងដែលមានបញ្ហាអោយបានឆាប់ដោយគ្មានឧបស័គ្គអ្វីឡើយ ។ ប្រទេសអ្នកទទួលត្រូវផ្តល់បុព្វសិទ្ធ និងអភ័យឯកសិទ្ធទាំងឡាយដល់ក្រុមបេសកកម្មស្វែងរកការពិតនេះ ដែលចាំបាច់ដើម្បីអោយគេធ្វើការងាររបស់គេមានប្រសិទ្ធភាព ដែលក្នុងនោះគ្មានមានការមិនរំលោភលើក្រដាសស្នាម ឯកសារ ការចាប់ខ្លួន ឃុំខ្លួន និងការចោទប្រកាន់លើអំពើ និងពាក្យសំដីដែលនិយាយក្នុងវត្ថុបំណងបំពេញបេសកកម្ម ។

៦. ប្រទេសអ្នកទទួលត្រូវមានសិទ្ធិក្នុងការការពារទីតាំងសំខាន់ៗ និងទប់ស្កាត់ការបែកខ្ចរខ្ចាយពត៌មានសំងាត់ និងទិន្នន័យដែលមិនមានទាក់ទងទៅនឹងសន្ធិសញ្ញានេះ ។

៧. ក្រុមបេសកកម្មស្វែងរកការពិតនៅក្នុងពេលបំពេញភារកិច្ចខ្លួនត្រូវ :

ក. គោរពរាល់ច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ប្រទេសអ្នកទទួល

ខ. បញ្ឈប់សកម្មភាពណាដែលមិនស្របទៅតាមគោលដៅ និងវត្ថុបំណងនៃសន្ធិសញ្ញានេះ

គ. ដាក់របាយការណ៍មុនដំបូង ឬបណ្តោះអាសន្នទៅគណៈកម្មាធិការប្រតិបត្តិ

ឃ. បញ្ចប់ភារកិច្ចរបស់ខ្លួនដោយមិនត្រូវយឺតយ៉ាវ ហើយត្រូវដាក់របាយការណ៍ចុងក្រោយជូនគណៈកម្មាធិការប្រតិបត្តិក្នុងពេលដ៏សមស្របមួយនៅពេលបញ្ចប់បេសកកម្មរបស់ខ្លួន ។

៨. គណៈកម្មាធិការប្រតិបត្តិត្រូវ :

ក/ពិនិត្យរបាយការណ៍ ដែលដាក់ជូនដោយក្រុមបេសកកម្មស្វែងរកការពិត ហើយធ្វើសេចក្តីសំរេចថា តើមាន ឬគ្មានការបំពានទៅលើសន្ធិសញ្ញា ។

ខ/បញ្ជូនសេចក្តីសំរេចរបស់ខ្លួនជាបន្ទាន់ទៅប្រទេសជាអ្នកសុំ និងប្រទេសជាអ្នកទទួល ហើយ

គ/ ធ្វើរបាយការណ៍យ៉ាងក្បោះក្បាយស្តីពីសេចក្តីសំរេចរបស់ខ្លួនជូនគណៈកម្មការ

៩. ក្នុងករណីដែលប្រទេសជាអ្នកទទួលមិនព្រមអនុវត្តន៍តាមសំណើសុំបេសកកម្មស្វែងរកការពិត ដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៤ទនោះ ប្រទេសជាអ្នកសុំត្រូវមានសិទ្ធិស្នើតាមរយៈគណៈកម្មាធិការប្រតិបត្តិសុំអោយមានកិច្ចប្រជុំនៃគណៈកម្មការ ។ គណៈកម្មាធិការប្រតិបត្តិត្រូវស្នើសុំជាបន្ទាន់ទៅគណៈកម្មការអោយបើកការប្រជុំមួយដូចមានចែងនៅក្នុងកថាខ័ណ្ឌទី៣ ង នៃមាត្រាទី ៩ ។

# ពិធីសារ

## លើសន្ធិសញ្ញាតំបន់ស្តីពីអាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ

**បណ្តារដ្ឋភាគីនៃពិធីសារនេះ**

**ដោយមានបំណង**ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើអោយការរំសាយសព្វាវុធនុយក្លេអ៊ែរ និងបានសំរេចទាំងស្រុងនិងជាទូទៅរួមចំណែកអោយបាននូវសន្តិភាព និងសន្តិសុខអន្តរជាតិ ដែលក្នុងនោះមានតំបន់អាស៊ី-អាគ្នេយ៍ផង

**ដោយគត់សំគាល់សន្ធិសញ្ញាតំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ**

**បានយល់ព្រមដូចតទៅ :**

### មាត្រាទី ១

រដ្ឋជាភាគីនិមួយៗប្រកាន់ខ្ជាប់ គោរពតាមសន្ធិសញ្ញាស្តីពីតំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ ដែល ពីនេះតទៅ ហៅថា " សន្ធិសញ្ញា " ហើយនឹងមិនចូលរួមក្នុងអំពើណាមួយ ដែលនាំអោយមានការរំលោភដោយបណ្តារដ្ឋជាភាគី លើសន្ធិសញ្ញា ឬក៏ពិធីសារនៃសន្ធិសញ្ញា ។

### មាត្រាទី ២

រដ្ឋជាភាគីនិមួយៗ មិនត្រូវប្រើ ឬគំរាម និងប្រើអាវុធនុយក្លេអ៊ែរប្រឆាំងនឹងរដ្ឋណាមួយជាភាគីនៃសន្ធិសញ្ញា ។ រដ្ឋជាភាគីនិមួយៗថែមទាំងប្រកាន់ខ្ជាប់មិនប្រើ ឬគំរាមនឹងប្រើអាវុធនុយក្លេអ៊ែរ នៅក្នុងតំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរឡើយ ។

### មាត្រាទី ៣

ពិធីសារនេះត្រូវបានបើកចំហជូនសាធារណ រដ្ឋប្រជាមានិតចិន បារាំង សហព័ន្ធរុស្ស៊ី ចក្រភពអង់គ្លេស និង អៀរឡង់ខាងជើង និងសហរដ្ឋអាមេរិក ចុះហត្ថលេខា ។

### មាត្រាទី ៤

រដ្ឋជាភាគីនិមួយៗ ត្រូវធ្វើការកត់សំគាល់របស់ខ្លួនជាលាយល័ក្សអក្សរផ្ញើទៅអោយប្រទេសជាអ្នកតំកល់សន្ធិសញ្ញា ដើម្បីបញ្ជាក់ពីការយល់ព្រមទទួលយក ឬពុំនោះសោតទេ សុំកែប្រែលើកាតព្វកិច្ចរបស់ខ្លួន

ចំពោះពិធីសារដែលអាចនាំអោយមិានឡើងការចូលជាធរមាននៃការធ្វើវិសោធនកម្មលើសន្ធិសញ្ញា ដែលយោល តាមមាត្រាទី ១៩នៃសន្ធិសញ្ញានេះ ។

## មាត្រាទី ៥

ពិធីសារនេះមានចរិតអចិន្ត្រៃយ៍ និងត្រូវមានតម្លៃមិនកំណត់នៅក្នុងលក្ខណ្ឌដែលរដ្ឋជាភាគីនិមួយ១ ត្រូវការអនុវត្តនូវអធិបតេយ្យភាពជាតិខ្លួន មានសិទ្ធិក្នុងការដកខ្លួនចេញពីពិធីសារនេះ បើគេសំរេចថាហេតុការណ៍ខុសពីធម្មតានោះ ដែលទាក់ទងដល់ពិធីសារ បានធ្វើអោយអន្តរាយដល់ឧត្តមប្រយោជន៍ជាតិរបស់ខ្លួន ។ រដ្ឋជាភាគីនោះត្រូវបញ្ជូនការបញ្ជាក់ពីការដកខ្លួននេះទៅប្រទេសតំកល់ឯកសារ ១២ខែមុន ។ ការបញ្ជាក់នោះត្រូវបញ្ចូលនូវសេចក្តីថ្លែងការណ៍ពីហេតុការណ៍ខុសធម្មតាដែលបានធ្វើអោយអន្តរាយដល់ឧត្តមប្រយោជន៍ជាតិ ។

## មាត្រាទី ៦

ពិធីសារនេះត្រូវទាមទារអោយមានការផ្តល់សច្ចាប័ន ។

## មាត្រាទី ៧

ពិធីសារនេះត្រូវចូលជាធរមានចំពោះរដ្ឋភាគីនិមួយ១ នៅពេលដែលសាមីរដ្ឋបានដាក់លិខិតុបករណ៍នៃសច្ចាប័នទៅប្រទេសតំកល់ឯកសារ ។ ប្រទេសតំកល់ឯកសារត្រូវជូនដំណឹងដល់បណ្តារដ្ឋដែលជាភាគីនៃសន្ធិសញ្ញា និងពិធីសារនេះ អំពីការដាក់លិខិតុបករណ៍នៃសច្ចាប័ន ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួនបានចុះហត្ថលេខាលើពិធីសារនេះ ។

ធ្វើនៅទីក្រុងបាងកក ថ្ងៃទីដប់ប្រាំ ខែធ្នូ ឆ្នាំមួយពាន់ប្រាំបួន រយកៅសិបប្រាំ ជាមួយច្បាប់ដើមជាភាសា អង់គ្លេស ។